ndis

# ការគាំទ្រជំនួសដែលអ្នកអាចចំណាយប្រាក់ NDIS លើវាបាន

Khmer | ភាសាខ្មែរ

ងាយស្រួលអាន (Easy Read)



## ជំនួយជាមួយនឹងឯកសារនេះ



អ្នកអាចរកនរណាម្នាក់ឲ្យជួយអ្នកបាន៖

- យល់ដឹងពីឯកសារនេះ
- ស្វែងរកព័ត៌មានបន្ថែម។



ព័ត៌មានទំនាក់ទំនងមាននៅចុងបញ្ចប់នៃឯកសារនេះ។

# អំពីឯកសារនេះ

ទីភ្នាក់ងារធានារ៉ាប់រងជនពិការថ្នាក់ជាតិ (NDIA) បាន សរសេរឯកសារនេះ។



នៅពេលយើងប្រើពាក្យថាយើង វាមានន័យថា NDIA។

យើងផ្តល់គម្រោងធានារ៉ាប់រងជនពិការថ្នាក់ជាតិ (National Disability Insurance Scheme) ឬ NDIS។



ឯកសារនេះនិយាយអំពីការគាំទ្រជំនួស ដែលអ្នកអាច ចំណាយមូលនិធិ NDIS លើវាបាន។

ការគាំទ្រជំនួសគឺជាការគាំទ្រដែល៖



- យើងបាននិយាយថាអ្នក **មិនអាច** ចំណាយប្រាក់ NDIS លើវាបានទេ
- សម្រាប់អ្នកដើម្បីប្រើប្រាស់ក្នុងករណីមួយចំនួន។

អ្នក**អាច** ត្រូវបានអនុញ្ញាតឱ្យទទួលបានការគាំទ្រជំនួស ប្រសិនបើយើងយល់ព្រម។



ការគាំទ្រជំនួសត្រូវតែ៖

- ជំនួសការគាំទ្រមួយដែលមាននៅក្នុងផែនការរបស់អ្នក
- ថ្លៃចំណាយដូចគ្នា ឬតិចជាងការគាំទ្រនៅក្នុងផែនការរបស់អ្នក
- ដូចគ្នា ឬល្អសម្រាប់អ្នកជាងការគាំទ្រនៅក្នុងផែនការរបស់អ្នក។



## ការគាំទ្រនានាដែលអ្នកអាចត្រូវបានអនុញ្ញាតឱ្យចំណាយប្រាក់ NDIS លើវាបាន

### របស់របរប្រើប្រាស់ក្នុងផ្ទះដែលជាធម្មតាមានលក់នៅទីផ្សារ



នេះមានន័យថាអ្វីទាំងឡាយសម្រាប់គេហដ្ឋានដែលត្រូវបានបញ្ជាក់ថាវាអាចជួយ៖

- ចំពោះតម្រូវការនៃអ្នកមានពិការភាព
- ឲ្យអ្នកមានភាពឯករាជ្យ។



មនុស្សមួយចំនួនអាចចំណាយប្រាក់ NDIS លើបច្ចេកវិទ្យាជំនួយបាន។

បច្ចេកវិទ្យាជំនួយមានន័យថាអ្វីទាំងឡាយដែលជួយជនពិការ។

## នាឡិកាឆ្លាតវៃ



នាឡិកាឆ្លាតវៃគឺជាអ្វីមួយដែល៖

- ភ្ជាប់ទៅនឹងអ៊ីនធឺណិត
- អ្នកអាចពាក់នៅលើកដៃរបស់អ្នកបាន។



អ្នក**អាច** ត្រូវបានអនុញ្ញាតឱ្យចំណាយប្រាក់ NDIS លើនាឡិកាឆ្លាតវៃមួយប្រសិនបើវា៖

- ជួយអ្នកក្នុងការប្រាស្រ័យទាក់ទង
- គឺជាមធ្យោបាយដ៏ល្អបំផុតសម្រាប់អ្នកប្រាស្រ័យទាក់ទង។

## ថេប្លេត



ថេប្លេតគឺជាអ្វីមួយដែល៖

- ភ្ជាប់ទៅនឹងអ៊ីនធឺណិត
- អ្នកអាចយកវាទៅណាជាមួយអ្នកបាន។



អ្នក**អាច** ត្រូវបានអនុញ្ញាតឱ្យចំណាយប្រាក់ NDIS លើថេប្លេតមួយ ប្រសិនបើវា៖

- ជួយអ្នកក្នុងការប្រាស្រ័យទាក់ទង
- គឺជាមធ្យោបាយដ៏ល្អបំផុតសម្រាប់អ្នកប្រាស្រ័យទាក់ទង។

## ទូរសព្ទស្មាតហ្វូន



ទូរសព្ទស្មាតហ្វូនគឺជាអ្វីមួយដែល៖

- ភ្ជាប់ទៅនឹងអ៊ីនធឺណិត
- អ្នកអាចយកវាទៅណាជាមួយអ្នកបាន។



អ្នក**អាច** ត្រូវបានអនុញ្ញាតឱ្យចំណាយប្រាក់ NDIS លើទូរសព្ទស្មាតហ្វូនមួយគ្រឿង ប្រសិនបើវា៖

- ជួយអ្នកក្នុងការប្រាស្រ័យទាក់ទង
- គឺជាមធ្យោបាយដ៏ល្អបំផុតសម្រាប់អ្នកប្រាស្រ័យទាក់ទង។

## កម្មវិធីនានាសម្រាប់ភាពងាយចូលប្រើប្រាស់ និងគោលបំណងប្រាស្រ័យទាក់ទង



កម្មវិធីនានាសម្រាប់ភាពងាយចូលប្រើប្រាស់ និងគោលបំណងប្រាស្រ័យទាក់ទងគឺជា កម្មវិធីនានាដែល៖

- អ្នកដាក់ឱ្យដំណើរការក្នុងអ្វីមួយ ដូចជាថេប្លេត
- ជួយអ្នកក្នុងការប្រាស្រ័យទាក់ទង។



អ្នក**អាច** ត្រូវបានអនុញ្ញាតឱ្យចំណាយប្រាក់ NDIS លើកម្មវិធីនានា ប្រសិនបើកម្មវិធីទាំងនោះ៖

- ជួយអ្នកក្នុងការប្រាស្រ័យទាក់ទង
- គឺជាមធ្យោបាយដ៏ល្អបំផុតសម្រាប់អ្នកក្នុងការប្រាស្រ័យទាក់ទង។

## ព័ត៌មានបន្ថែមអំពីឯកសារនេះ

សម្រាប់ព័ត៌មានបន្ថែមអំពីឯកសារនេះ សូមទាក់ទងមកយើង។



### អ្នកអាចហៅទូរសព្ទមកយើងបាន

1800 800 110



### អ្នកអាចផ្ញើអ៊ីមែលមកយើង

enquiries@ndis.gov.au



### អ្នកអាចមកកាន់ការិយាល័យរបស់យើងផ្ទាល់បាន

អ្នកអាចស្វែងរកការិយាល័យក្នុងតំបន់របស់អ្នកនៅលើគេហទំព័រ NDIS។

ndis.gov.au/contact/locations

## ស្វែងយល់បន្ថែមទៀតអំពី NDIA




### ចូលមើលគេហទំព័ររបស់យើង

[ndis.gov.au](ndis.gov.au)

### តាមដានយើងនៅលើបណ្ដាញសង្គមរបស់យើង

Facebook, Twitter, Instagram,
YouTube, LinkedIn

# រកជំនួយដើម្បីទាក់ទងមកយើង

## សម្រាប់អ្នកដែលត្រូវការជំនួយជាភាសាអង់គ្លេស



អ្នកអាចហៅទូរសព្ទទៅសេវាបកប្រែភាសាសរសេរ និងផ្ទាល់មាត់ (TIS)។

131 450

## សម្រាប់មនុស្សថ្លង់ ឬពិបាកស្តាប់




អ្នកអាចប្រើប្រាស់សេវាកម្មជាតិផ្នែកប្រាស្រ័យទាក់ទងជាមួយ ជនពិការ (National Relay Service)

relayservice.gov.au



អ្នកអាចប្រើមុខងារទូរសព្ទជាអក្សរ (TTY) បាន។

1800 555 677



អ្នកអាចប្រើការបញ្ជូនបន្តជាសំឡេងបាន។

1800 555 727

ឯកសារងាយស្រួលអាននេះត្រូវបានបង្កើតឡើងដោយក្រុមហ៊ុន Scope (Aust) Ltd. ក្នុងខែវិច្ឆិកា ឆ្នាំ 2024 ដោយប្រើនិមិត្តសញ្ញាទំនាក់ទំនងតាមរូបភាព (PCS)។ PCS គឺជាពាណិជ្ជសញ្ញារបស់ Tobii Dynavox, LLC។ រក្សាសិទ្ធិគ្រប់យ៉ាង។ ប្រើប្រាស់ដោយមានការអនុញ្ញាត។ ឯកសារនេះមិនត្រូវលក់ទៅឱ្យភាគីទីបីទេ។ រូបភាពនានានោះមិនត្រូវប្រើប្រាស់ឡើងវិញដោយគ្មានការអនុញ្ញាតឡើយ។ សម្រាប់ព័ត៌មានបន្ថែមអំពីរូបភាពនានានោះ សូមទាក់ទងក្រុមហ៊ុន Scope តាមលេខ 1300 472 673 ឬចូលមើលគេហទំព័រ scopeaust.org.au